នស/រកម/០៨០៦/០២២

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ២ និងមាត្រា ១៥
# នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម

**មាត្រាតែមួយ.-**

មាត្រា ២ និងមាត្រា ១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម ដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ២ ថ្មី.-**

សភាពាណិជ្ជកម្មនៅតាមខេត្ត ក្រុងនីមួយៗ ត្រូវបង្កើតឡើងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

ព្រំដែនមណ្ឌលនៃសភាពាណិជ្ជកម្មនីមួយៗ ត្រូវកំណត់ឡើងដោយអនុក្រឹត្យដែលបង្កើតសភាពាណិជ្ជកម្មនោះ ។

សភាពាណិជ្ជកម្មខេត្ត ក្រុង ប្រមូលផ្តុំបង្កើតជាសភាពាណិជ្ជកម្មថ្នាក់ជាតិមួយឈ្មោះហៅថា សភាពាណិជ្ជកម្មកម្ពុជា ដែលធ្វើសកម្មភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំ និងការប្រព្រឹត្តទៅព្រមទាំងភារកិច្ចរបស់សភាពាណិជ្ជកម្មកម្ពុជានឹងត្រូវកំណត់

ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា១៥ ថ្មី .-

ចំណាយសម្រាប់ការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម ត្រូវផ្គត់ផ្គង់ដោយ :

-វិភាគទានរបស់សមាជិក

-អំណោយក្នុងនិងក្រៅប្រទេស

-ចំណូលមកពីការគ្រប់គ្រងគ្រឹះស្ថាន និងការដេញថ្លៃនានា

-ចំណូលព្រមទាំងវិភាគទានមកពីប្រភពផ្សេងៗ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៦០៨.៣៤៣ នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម ប្រសិទ្ធ

លេខ : 646 ពណ.រប.ចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក

- ថ្នាក់ដឹកនាំក្រសួង " មេត្តាជ្រាប "

- អគ្គនាយកដ្ឋាន-អគ្គាធិការដ្ឋាន-ខុទ្ទកាល័យ

គ្រប់នាយកដ្ឋាន-ក្រុមហ៊ុនម្រ្តីនគ្រេដ - មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង

និង សភាពាណិជ្ជកម្មខេត្ត-ក្រុង

- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ.ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៦

តប.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

/ន.ប្រធាននាយកដ្ឋានរដ្ឋបាល /

វ៉ង់ ច័ន្ទតារា

លេខ : ៣៤៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន